# ប្រវត្តិសាលារចនា

ដោយ ព្រាប ចាន់ម៉ារ៉ា

សាលារចនាខេមរៈ (ឬសាលាសិល្បៈខេមរៈ) ជាភាសាបារាំងហៅថា École des arts cambodgiens ហើយដែលអ្នកផងទូទៅហៅថា «សាលារចនា» គឺបង្កើតឡើងតាមព្រះរាជក្រឹត្យនៃព្រះករុណាព្រះបាទសម្តេចព្រះស៊ីសុវត្ថិ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩១៧ ដោយមានលោក George Groslier (១៨៨៧-១៩៤៥) ដែលអភិបាលបារាំងប្រចាំឥណ្ឌូចិនបញ្ជូនមកឲ្យជួយរៀបចំសាលានេះ (រូបលេខ១)។ លោក George Groslier បានចាត់ចែងឲ្យមានកម្មវិធីដើម្បី «លើកស្ទួយសិល្បៈខ្មែរឲ្យមានមុខមាត់ថ្មី »។ សូមជ្រាបថា សិល្បៈខ្មែរជំនាន់នោះប្រឈមនឹងការបាត់បង់ជាបណ្តើរៗដែរ ទើបត្រូវរៀបចំឲ្យមានអត្តសញ្ញាណវប្បធម៌ផ្ទាល់ខ្លួនរបស់ខ្មែរ ពោលគឺមិនក្លាយតាមបែបប្រទេសជិតខាង។ ជាមួយគ្នានឹងសាលារចនានេះ លោក George Grolier បានរៀបចំឲ្យមានសារមន្ទីរមួយដែរ ដោយចាប់សាងសង់អគារនៅកំឡុងឆ្នាំ១៩១៨។



១. លោក George Grolier អង្គុយលើកៅអី (ប្រភពរូប៖ សារមន្ទីរជាតិ)។

ពេលបង្កើតសាលារចនាដំបូងនោះ គេធ្វើអគារជាប់គ្នានឹងអគារសារមន្ទីរ គឺអគារសាលារចនាជាថែវមានដំបូលរាងជាផ្ទះខ្មែរព័ទ្ធពីទិសខាងជើង ខាងលិច និងខាងត្បូង (រូបលេខ២-៥)។ ឯអគារសារមន្ទីរជាថែវមួយល្វែង ដំបូលមានកំពូលមណ្ឌបស្រួចចំនួនបីនៅជាប់ពីផ្នែកខាងកើតសាលារចនានេះ (រូបលេខ៦-៨)។ ជាមួយគ្នានោះក៏មានសាងអគារសម្រាប់សាលានៅពីខាងលិច ដែលទម្រង់ប្លង់បាតជាថែវព័ទ្ធទីធ្លាកណ្ដាលស្មើរដូចនឹងអគារសាងនៅពីខាងកើតនោះដែរ (រូបលេខ៩) ហើយក្រោយមកអគារនេះបន្តធ្វើជាសាលារចនារហូតដល់សព្វថ្ងៃ។ សាលារចនានិងសារមន្ទីរជាមណ្ឌលរួមតែមួយ ដ្បិតវិស័យសិល្បៈនេះមានតួនាទីសិក្សានិងផ្សព្វផ្សាយនៅជាមួយគ្នា ហើយផ្សារភ្ជាប់រវាងសិល្បៈខ្មែរសម័យបុរាណនិងសិល្បៈខ្មែរសម័យថ្មីផង។ សារមន្ទីរគឺជាកន្លែងតាំងបង្ហាញវត្ថុបុរាណ ពិសេសស្នាដៃខាងសិល្បៈ ឯសាលារចនាជាកន្លែងបណ្ដុះបណ្ដាលនិងមានសកម្មភាពជាក់ស្ដែងខាងសិល្បៈយ៉ាងរស់រវើក ពោលគឺស្ថាប័នទាំងពីរនេះមានទំនាក់ទំនងគ្នាជិតស្និតខាងវិស័យសិល្បៈខ្មែរបុរាណនិងសិល្បៈខ្មែរសម័យថ្មីដ៏ប្រសើរបំផុត។ នៅថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩២០ ទើបព្រះករុណាព្រះបាទសម្ដេចព្រះស៊ីសុវត្ថិ យាងមកសម្ពោធសារមន្ទីរនិងសាលារចនានេះ។



២. ថែវខាងលិចរបស់សាលារចនាដំបូង, ថតពីទិសនិរតីនៃបរិវេណខាងក្នុង (ប្រភពរូប៖ សារមន្ទីរជាតិ)។



៣. ថែវខាងជើងនិងខាងលិចរបស់សាលារចនាដំបូង, ថតពីទិសអាគ្នេយ៍នៃបរិវេណខាងក្នុង (ប្រភពរូប៖ សារមន្ទីរជាតិ)។



៤. ថែវខាងលិចរបស់សាលារចនាដំបូង, ថតពីទិសពាយព្យ (ប្រភពរូប៖ ស្រង់ពីសៀវភៅ Cérémonie D'inauguration du Musée Albert Sarraut et de L'école des Arts Cambobgiens, Imprimerie du Protectorat, Phnom Penh, 1920.)។



៥. ថែវខាងត្បូងរបស់សាលារចនាដំបូង, ថតពីទិសនិរតី (ប្រភពរូប៖ ស្រង់ពីសៀវភៅ Cérémonie D'inauguration du Musée Albert Sarraut et de L'école des Arts Cambobgiens, Imprimerie du Protectorat, Phnom Penh, 1920.)។



៦. អគារសារមន្ទីរ (មានខឿន) សាងជាប់គ្នានឹងថែវសាលារចនា (អត់មានខឿន) ថតពីទិសពាយព្យនៃបរិវេណខាងក្នុង (ប្រភពរូប៖ សារមន្ទីរជាតិ)។



៧. អគារសារមន្ទីរ, ថតពីមុខ ទិសខាងកើត (ប្រភពរូប៖ ស្រង់ពីសៀវភៅ Cérémonie D'inauguration du Musée Albert Sarraut et de L'école des Arts Cambobgiens, Imprimerie du Protectorat, Phnom Penh, 1920.)។




៨. សាលារចនាដំបូងមានអគារជាប់គ្នានឹងអគារសារមន្ទីរ។



៩. អគារមួយទៀតនៃសាលារចនានៅខាងលិច, ថតពីទិសខាងកើត (ប្រភពរូប៖ សារមន្ទីរជាតិ)។

នៅពេលបង្កើតសាលារចនាថ្មីនេះជាផ្លូវការហើយ គេបានផ្ទេរក្រុមសិល្បករសាលារចនារបស់ព្រះបរមរាជវាំង (ដែលបង្កើតតាំងពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩១២) រួមជាមួយនឹងសិល្បករចំណានៗដែលគេប្រមូលពីទីផ្សេងៗមកធ្វើជាគ្រូនៅទីនេះវិញ។ ទាំងខាងពេងជាងកិច្ចការរចនា ទាំងខាងរបាំព្រះរាជទ្រព្យ (ល្ខោនហ្លួង) និងក្រុមភ្លេងជាដើម (រូបលេខ១០) នៅតែមាននាទីជាប់ជាមួយព្រះបរមរាជវាំងផង និងសាធារណៈទូទៅផង។

គួរជ្រាបបន្តិចដែរថា ចាប់តាំងពីរវាងឆ្នាំ១៩០៧មកម្ល៉េះ ដែលគេនាំគ្នាគិតគូររៀបចំក្រុមសិល្បៈនានាដែលមានជាប្រពៃណីរបស់ព្រះបរមរាជវាំងតាំងពីបុរាណឲ្យកើតទៅជាសាលារចនានេះ ក្នុងនោះមានការជួយជ្រោមជ្រែងខ្លាំងពីចៅហ្វាវាំង ជួន (១៨៦៤-១៩៤៦) ដែរ រហូតដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩១២ ទើបមានព្រះរាជប្រកាសមួយបង្កើតសាលារចនានៅក្នុងព្រះបរមរាជវាំង (ជាភាសាបារាំងហៅថា École royale des Arts décoratifs) ដែលផ្តោតលើការងាររចនាតុបតែងផ្សេងៗ។ ក្រុមសិល្បៈនេះឯងដែលជាមូលដ្ឋានឲ្យគេបង្កើតទៅជា «សាលារចនា» ផ្លូវការនៅឆ្នាំ១៩១៧នោះ និងបន្តរហូតមកទល់បច្ចុប្បន្ននេះ។




១០. សាស្ត្រាចារ្យនិងសិស្សសាលារចនា ឆ្នាំ១៩២០ (ប្រភពរូប៖ ស្រង់ពីសៀវភៅ Cérémonie D’inauguration du Musée Albert Sarraut et de L’école des Arts Cambobgiens, Imprimerie du Protectorat, Phnom Penh, 1920.)។

នៅច្រើនឆ្នាំក្រោយមក គេផ្ទេរអគារសាលារចនាដែលជាប់ថែវនៅជាប់គ្នានឹងអគារសារមន្ទីរនោះ ឲ្យទៅធ្វើជាសារមន្ទីរទាំងស្រុង។ សាលារចនាទុកនៅតែផ្នែកខាងលិចដែលមានអគារដាច់ដោយឡែកនោះប៉ុណ្ណោះ (រូបលេខ១១-១៣) និងសាងអគារថ្មីៗថែមទៀតក្នុងបរិវេណសាលានៅពេលបន្តបន្ទាប់មក (រូបលេខ១៤-១៦)។ ចំពោះការងារផ្សេងៗនៅតែមានទំនាក់ទំនងគ្នារវាងសាលារចនានិងសារមន្ទីរជាធម្មតា ដោយពុំមានខណ្ឌដាច់ពីគ្នាទេ។




១១. សាលារចនានៅបរិវេណខាងលិចសារមន្ទីរ។



១២. អគារមួយនៃសាលារចនា, ថតពីទិសខាងកើត (ប្រភពរូប៖ សារមន្ទីរជាតិ)។



១៣. សាស្ត្រាចារ្យនៃសាលារចនា (ប្រភពរូប៖ ?)។



១៤. អគារមួយថែមទៀតដែលគេសាងប្រហែល ទសវត្ស១៩៥០ ក្នុងសាលារចនា។



១៥. អគារខ្ពស់នៅកណ្ដាល ក្នុងសាលារចនា គេសាងថែមនៅរវាងឆ្នាំ១៩៦៤-៦៥។



១៦. ធ្លានៅចន្លោះអគារផ្នែកខាងលិចក្នុងសាលារចនា។

សាលារចនានៅក្រុងភ្នំពេញនេះ ស្ថិតនៅខាងជើងព្រះបរមរាជវាំង និងនៅខាងលិចនៃវាលព្រះសុមេរុ (វាលមេន) ហើយមានសារមន្ទីរនៅជាប់ពីខាងកើតនៃសាលានេះ (រូបលេខ១៧-១៨)។ ទីតាំងដែលរៀបចំសាលារចនាឡើងជាប់នឹងព្រះបរមរាជវាំង មិនមែនជាការចៃដន្យទេ គឺជាទំនៀមតៗមកពីសម័យបុរាណកាល ដ្បិតសិល្បៈប្រណីតៗតែងជាប់ទាក់ទងនឹងព្រះរាជវាំង ហើយគ្រូចំណានៗក៏ជាសិល្បកររបស់ព្រះរាជវាំងដែរ។ បើយើងសម្លឹងមើលឲ្យវែងឆ្ងាយដល់ខ្មែរសម័យបុរាណព្រេងនាយឯណោះ ទើបយើងយល់អំពីខ្មែរសម័យថ្មី ឬផ្ទុយទៅវិញ គឺយើងមើលអ្វីៗដែលសេសសល់ដល់សម័យបច្ចុប្បន្ននេះ ទើបយើងដឹងថាមរតកទាំងអម្បាលម៉ានគឺជាកេរ្តិ៍តៗគ្នាមកឥតដាច់ពីខ្មែរសម័យបុរាណនោះឯង។ នៅដើម ស.វ.ទី៩ ព្រះបាទជ័យវរ្ម័នទី២សាងរាជធានីមួយឈ្មោះថា «ហរិហរាល័យ» ស្ថិតនៅតំបន់រលួស ក្នុងខេត្តសៀមរាបសព្វថ្ងៃ ហើយក្រុងនេះចេះតែរីកដុះដាលក្នុងរាជ្យស្តេចបន្តបន្ទាប់មក។ នៅទីនោះមានប្រាសាទតូចធំច្រើនដែរ ហើយអ្នកស្រាវជ្រាវគិតថាព្រះបរមរាជវាំងក្រុងហរិហរាល័យនេះ គឺតាំងនៅត្រង់តំបន់ប្រាសាទព្រៃមន្ទីរ (ព្រះមន្ទីរ?) ព្រោះទីនោះមាន




១៧. ទីតាំងសាលារចនានៅក្បែរនឹងកំពែងខាងជើងនៃព្រះបរមរាជវាំង។



១៨. ខាងឆ្វេងជាសាលារចនា ស្ថិតនៅក្បែរកំពែងខាងជើងនៃព្រះបរមរាជវាំង។

កំពែងដីនិងកសិន្ធុទឹកព័ទ្ធជុំវិញរាងបួនជ្រុង គឺលិច-កើតប្រវែងជិត៨០០ម. និងជើង-ត្បូងជាង៥០០ម. និងមានប្រាសាទនៅក្នុងនោះផង។ ការធ្វើកំណាយស្រាវជ្រាវផ្នែកបុរាណវិទ្យាដឹកនាំដោយលោក Martin Polkinghorne កាលពីប៉ុន្មានឆ្នាំកន្លងទៅ គេរកឃើញសំណល់វត្ថុសិល្បៈជាច្រើន ដែលគេធ្វើពុំទាន់ស្រេចបាច់ នៅត្រង់មុំខាងលិចប្រាសាទបាគង ដែលនៅពីខាងជើងនៃព្រៃមន្ទីរនេះ ហើយគេយល់ថាទីនោះគឺជារោងជាងសិល្បៈរបស់ព្រះរាជវាំងនេះឯង។

លុះមកដល់ចុងស.វ.ទី៩ ព្រះបាទយសោវរ្ម័នទី១ សាងរាជធានីថ្មីមួយឈ្មោះថា «យសោធរ» នៅក្នុងទីតាំងដែលសព្វថ្ងៃយើងហៅថាតំបន់អង្គរ ហើយទីនោះចេះតែរីកចុំរើនឡើងជាលំដាប់ពីរាជ្យស្តេចមួយអង្គទៅមួយអង្គ រហូតដល់ស.វ.ទី១២។ ក្រុងនេះមានព្រះបរមរាជវាំងនៅក្នុងបរិវេណអង្គរធំ គឺខាងពាយព្យប្រាសាទបាយ័ន្ត ហើយមានទីតាំងសំខាន់ជាងគេចាប់ពីព្រះលានដល់ដំរីទៅទិសខាងលិច និងមានកំពែងថ្មបាយក្រៀមពីរជាន់ព័ទ្ធរាងបួនជុង គឺលិច-កើតប្រវែងជាង៥៨០ម. និងជើង-ត្បូងជាង២៤០ម. ហើយមានប្រាសាទនិងស្រះទឹកខ្វះនៅក្នុងនោះ។ នៅខាងជើងកំពែងព្រះរាជវាំងនេះក៏អ្នកស្រាវជ្រាវផ្នែកបុរាណវិទ្យា ដឹកនាំដោយលោក Martin Polkinghorne ដែរធ្វើកំណាយឃើញមានសំណល់លោហៈធាតុជាច្រើន ដែលគេសិតធ្វើជាវត្ថុសិល្បៈផ្សេងៗ។ ដូច្នោះទីនេះក៏មិនខុសពីព្រះរាជវាំងមុនដែរ ពោលគឺមានរោងជាងសិល្បៈស្ថិតនៅជាប់នឹងព្រះរបមរាជវាំងជានិច្ច។

ឥឡូវយើងពិចារណាមកសម័យកណ្តាលបន្តិចមើល។ គ្រឿងអលង្ការក្តី សម្ភារៈប្រើប្រាស់ក្តី វត្ថុសក្ការៈផ្សេងៗក្តី ពិសេសរបស់ដែលល្អៗខ្ពង់ខ្ពស់សម្រាប់ព្រះនគរ សម្រាប់ព្រះមហាក្សត្រ ឬនាម៉ឺនតូចធំ សេដ្ឋីគហបតីជាដើម រមែងមានក្រុមសិល្បករឆ្នើមៗជាអ្នកស្និតស្នាងឡើង។ អ្វីដែលមានកម្រិតឧត្តុង្គឧត្តម ប្រណីតថ្លៃថ្លា គឺមានតែចេញមកពីរោងជាង

ព្រះបរមរាជវាំងនេះឯងហើយ។ ក្នុងប្រពៃណីព្រះមហាក្សត្រខ្មែរតាំងតែពីបុរាណកាលមក ក៏ដូចជាអ្នកមានបណ្ដាសក្តិខ្ពស់ៗ តែងតែមានការប្រទានរបស់ទ្រព្យចំពោះអ្នកមានគុណ បំណាច់ផ្សេងៗ ឬក៏សម្រាប់ថ្វាយទៅទេព ឬមួយប្រគេនបព្វជិតនានាជាដើម គឺគេប្រើរបស់របរប្រកបដោយសិល្បៈវិចិត្ររចនានេះជាការចាំបាច់ ហើយចាត់ទុកថាជាការថ្លៃថ្នូរក្នុងវប្បធម៌ខ្មែរទៀតផង (សព្វថ្ងៃក៏នៅតែមានជាធម្មតា)។ ក្នុងគំនិតដូច្នេះហើយបានជាព្រះបរមរាជវាំងខ្មែរតែងតែមានរោងជាងសិល្បៈ (សាលារចនា) តាំងនៅជាប់ជានិច្ច។ សិល្បៈនោះមិនត្រឹមតែមានគ្រឿងអលង្ការ, របស់ប្រើប្រាស់, វត្ថុជាទីសក្ការៈប៉ុណ្ណោះទេ គឺមានរហូតដល់ទៅគ្រឿងរចនាសាងសង់ គ្រឿងស្លៀកពាក់ តាក់តែងកាយ និងតូរ្យតន្ត្រី ព្រមទាំងល្បែងរបាំល្ខោននាដសាស្ត្រផ្សេងៗផង។ នៅស.វ.ទី១៧ រាជធានីខ្មែរតាំងនៅឧត្តុង្គ មានព្រះបរមរាជវាំងស្ថិតនៅម្តុំវត្តវាំងចាស់សព្វថ្ងៃ ហើយទីនោះក៏ដូចសម័យបុរាណ គឺមានសិល្បករជាជាងស្មិតលោហៈល្បីៗនៅភាគខាងជើងនិងពាយព្យភ្នំឧត្តុង ហើយនៅក្បែរនឹងអតីតព្រះរាជវាំងនោះដែរ។ ជាមួយគ្នានេះក៏មានក្រុមជាងទងចំណានៗ ដែលសព្វថ្ងៃតាំងនៅម្តុំកំពង់ហ្លួង ហើយទាំងជាងស្មិត ទាំងជាងទងបានរីកដុះដាលទៅជាសហគមន៍សិល្បករយ៉ាងធំទូលាយរហូតមកដល់បច្ចុប្បន្ន។

មកដល់សម័យថ្មីឯណោះវិញ ភ្នំពេញបានក្លាយជារាជធានីជាប់លាប់ លែងផ្លាស់ប្តូរទៅណាតាំងពីរវាងចុងស.វ.ទី១៩មក ហើយព្រះបរមរាជវាំងថ្មីក៏មានរចនាសម្ព័ន្ធទូទៅមិនខុសឆ្ងាយពីអតីតកាលឡើយ។ នេះមកពីផ្នត់គំនិតជាប់តៗគ្នារឹងមាំក្លាយទៅជាអារ្យធម៌មួយដែលមានមរតកបុរាណជាឫសគល់ច្បាស់លាស់ ទើបការរៀបចំក្រុងក្តី ការរៀបចំព្រះបរមរាជវាំងក្តី និងរចនាសម្ព័ន្ធពាក់ព័ន្ធនានាមានខ្សែគំនិតហូរហែវែងឆ្ងាយឥតដាច់យ៉ាងដូច្នេះ។ តាមពិតទៅនៅមានអ្វីៗជាច្រើនទៀតដែលគួរឲ្យយើងយល់ដឹងបានទូលំទូលាយអំពីខ្លឹម

សារនៃសាលារចនា ប៉ុន្តែរឿងនេះគ្រាន់តែពិចារណាបន្តិចបន្តួចប៉ុណ្ណោះទៅ ក៏គង់នឹងយល់ហើយថា ព្រះបរមរាជវាំងនិងសាលារចនាហាក់ដូចជាសម្ព័ន្ធរវាង «មនុស្សនិងសិល្បៈ» ថ្នាក់ខ្ពស់របស់ព្រះនគរ។ ទោះបីជាសម័យកាលថ្មីឈានដល់ទេសកាលផ្សេងក៏ដោយ ក៏តម្លៃជាក់ស្តែងនោះនៅតែមាន ហើយតម្លៃជាប្រវត្តិសាស្ត្រ វប្បធម៌ និងកេរ្តិ៍ដំណែលជាតិក៏រឹងរឹតតែខ្ពង់ខ្ពស់។ គួរជ្រាបដែរថា មានប្រទេសជិតខាងខ្លះដែលទទួលឥទ្ធិពលអារ្យធម៌ខ្មែរទៅក៏រៀបចំរចនាសម្ព័ន្ធស្ថាប័ននិងទីតាំងព្រះបរមរាជវាំងនិងសាលារចនារបស់គេតាមរបៀបដូច្នេះដែរ។

តើសាលារចនានៅភ្នំពេញមាន «ដំណើរជីវិត» របស់ខ្លួនយ៉ាងណាតាំងពីចាប់កំណើតរហូតមកដល់គ្រានេះ?

កន្លងមកមានអ្នកស្រាវជ្រាវច្រើនគ្នា ដែលបានសិក្សាអំពីរឿងរ៉ាវរបស់សាលារចនា ពិសេសជនបរទេស ហើយបានបោះពុម្ពផ្សព្វផ្សាយខ្លះ ឯខ្លះពុំទាន់បានបោះពុម្ពផ្សាយ និងខ្លះទៀតសិក្សាក្នុងក្របខ័ណ្ឌនិក្ខេបបទថ្នាក់បណ្ឌិតផងក៏មានដែរ ដែលបញ្ជាក់ថាសាលានេះមានកេរ្តិ៍ឈ្មោះបោះសម្លេងវែងឆ្ងាយយូរមកហើយ។ នៅទីនេះខ្ញុំនិយាយត្រួសៗទេដើម្បីស្វែងយល់ដោយសង្ខេបៗអំពីការងាររបស់សាលារចនា។

ចាប់តាំងពីដំណើរការបន្តិចម្តងៗនៅឆ្នាំ១៩១៨មក សាលារចនានេះមានសកម្មភាពជាច្រើនដែលត្រូវធ្វើ ហើយជាពិសេសក្រុមការងាររចនាផ្នែកសំណង់ ទាំងគ្រូ ទាំងសិស្សចំណានៗ គឺមាននាទីជួយរៀបចំតុបតែងលម្អគ្រឿងអគារសារមន្ទីរ ដែលសាងនៅជាប់ជាមួយគ្នានេះ និងតុបតែងបង្ហើយនាឆ្នាំ១៩១៩-២០ (រូបលេខ១៩-២០)។ រីឯព្រះបរមរាជវាំង

ដែលត្រូវរៀបចំកែលម្អ និងសាងសង់ព្រះទីនាំង ឬព្រះដំណាក់ ព្រមទាំងសម្ភារៈតាក់តែងប្រណីតថ្មីៗ ក៏ត្រូវការជាចាំបាច់ពីក្រុមសិល្បករទាំងនោះដែរ។



១៩. សាស្ត្រាចារ្យនិងសិស្សសាលារចនា តុបតែងអគារសារមន្ទីរ (ប្រភពរូបៈ សារមន្ទីរជាតិ)។



២០. សាស្ត្រាចារ្យនិងសិស្សសាលារចនា គូរគំនូរលើបង្អួចអគារសារមន្ទីរ (ប្រភពរូបៈ សារមន្ទីរជាតិ)។

ក្នុងសាលារចនាសម័យនោះមានផ្នែកជំនាញផ្សេងៗជាច្រើនដូចជា៖ ផ្នែកចម្លាក់ឈើ (រូបលេខ២១-២២), ផ្នែកស្មិត (រូបលេខ២៣-២៥), ផ្នែកជាងទង (រូបលេខ២៦-២៧), ផ្នែកគំនូរ (រូបលេខ២៨), ផ្នែកចម្លាក់ពុម្ព (រូបលេខ២៩-៣០), ផ្នែកសំណង់, ផ្នែកមុខខ្នុក (រូបលេខ៣១-៣៣), ផ្នែកតម្បាញសូត្រ (រូបលេខ៣៤-៣៥), ផ្នែករបាំ (រូបលេខ៣៦-៣៨), ផ្នែកភ្លេង (រូបលេខ៣៩)។ល។ ដែលការងារទាំងអស់នេះទាមទារឲ្យមានការរៀបចំគ្រប់គ្រងចាត់ចែង



២១. ផ្នែកចម្លាក់ឈើនៅសាលារចនា (ប្រភពរូបៈ សារមន្ទីរជាតិ)។



២២. ផ្នែកចម្លាក់ឈើនៅសាលារចនា (ប្រភពរូបៈ សារមន្ទីរជាតិ)។



២៣. ផ្នែកស្មិតនៅសាលារចនា
(ប្រភពរូបៈ សារមន្ទីរជាតិ)។



២៤. ផ្នែកស្មិតនៅសាលារចនា
(ប្រភពរូបៈ សារមន្ទីរជាតិ)។



២៥. ផ្នែកស្មិតនៅសាលារចនា
(ប្រភពរូបៈ សារមន្ទីរជាតិ)។



២៦. ផ្នែកជាង៍ទង៍នៅសាលារចនា
(ប្រភពរូបៈ សារមន្ទីរជាតិ)។



២៧. គ្រឿង៍ប្រាក់ធ្វើនៅសាលារចនា
(ប្រភពរូបៈ សារមន្ទីរជាតិ)។



២៨. ផ្នែកគំនូរនៅសាលារចនា
(ប្រភពរូបៈ សារមន្ទីរជាតិ)។



២៩. ផ្នែកចម្លាក់ពុម្ពនៅសាលារចនា
(ប្រភពរូបះ សារមន្ទីរជាតិ)។



៣០. ផ្នែកចម្លាក់ពុម្ពនៅសាលារចនា
(ប្រភពរូបះ សារមន្ទីរជាតិ)។




៣១. ផ្នែកមុខខ្នុកនៃសាលារចនា
(ប្រភពរូបះ សារមន្ទីរជាតិ)។



៣២. គ្រូធ្វើមុខខ្នុកនៅសាលារចនា
(ប្រភពរូបះ សារមន្ទីរជាតិ)។



៣៣. មកុដធ្វើនៅសាលារចនា
(ប្រភពរូបះ សារមន្ទីរជាតិ)។




៣៤. ផ្នែកតម្បាញនៅសាលារចនា
(ប្រភពរូបះ សារមន្ទីរជាតិ)។



៣៥. ផ្នែកតម្បាញនៅសាលារចនា (ប្រភពរូបៈ សារមន្ទីរជាតិ)។



៣៦. ពិធីសំពះគ្រូផ្នែករបាំនៅសាលារចនា (ប្រភពរូបៈ សារមន្ទីរជាតិ)។



៣៧. សិស្សផ្នែករបាំនៅសាលារចនា (ប្រភពរូបៈ សារមន្ទីរជាតិ)។



៣៨. គ្រូនិងសិស្សផ្នែករបាំថតជាមួយលោក George Groslier (ប្រភពរូបៈ សារមន្ទីរជាតិ)។




៣៩. គ្រូរបាំនិងគ្រូភ្លេងនៅសាលារចនា (ប្រភពរូបៈ សារមន្ទីរជាតិ)។

ម៉ត់ចត់ ទាំងផ្នែកតាមរបៀបប្រពៃណី ទាំងផ្នែកតាមរបៀបការបង្កើតថ្មីៗ លោក George Groslier ជាចាងហ្វាងត្រួតកិច្ចការដ៏ធំធេងរបស់សាលារចនាផង (រូបលេខ២០) ការងារសាងសង់សារមន្ទីរផង ហើយជួនកាលត្រូវជួយគិតគូរជាមួយនឹងសិល្បករខ្មែរក្នុងការតុបតែងព្រះបរមរាជវាំងផង ក៏ខិតខំពុះពារធ្វើជាមួយសាស្ត្រាចារ្យខ្មែរជំនាញៗជាលំដាប់ពុំដែលដាច់ រហូតដល់លោកសាងទីស្នាក់អាស្រ័យនៅធ្វើការក្នុងសាលានេះ (រូបលេខ២១) ដើម្បីជួយសម្រួលដល់ការគ្រប់គ្រងទៀតផង។



២០. លោក George Groslier ជាចាងហ្វាងសាលារចនា (ប្រភពរូប៖ សារមន្ទីរជាតិ)។



២១. ផ្ទះសម្រាប់លោក George Groslier ស្នាក់ធ្វើការនៅក្នុងសាលារចនា (ប្រភពរូប៖ សារមន្ទីរជាតិ)។

សាលារចនាជំរុញឲ្យមានការប្រឡងប្រជែងបញ្ចេញស្នាដៃ និងគំនិតច្នៃប្រឌិតថ្មីៗ រហូតដល់មានការតាំងពិព័រណ៍បង្ហាញការងារខ្លួនជាហូរហែ ទោះបីជាមានឧបសគ្គខ្លះៗដែលចៀសពុំរួចក៏ដោយ។ មិនត្រឹមតែនៅក្នុងស្រុកទេ សូម្បីតែពិព័រណ៍ដ៏ធំធេងនៅស្រុកបារាំងអំពីប្រទេសស្ថិតក្រោមអាណានិគមបារាំង ដែលធ្វើឡើងកាលពីរវាងទសវត្សរ៍១៩៣០ ក៏សាលារចនាចូលរួមយ៉ាងសកម្ម តាំងពីការងារសាងសង់រូបប្រាសាទអង្គរវត្ត ព្រហ្មបាយ័ន្ត

ចម្លង់រូបក្បាច់រចនា ផ្ទាំងចម្លាក់ បដិមា និងការសម្តែងសិល្បៈផ្សេងៗយ៉ាងគគ្រឹកគគ្រេង ធ្វើឲ្យរដ្ឋការបារាំងសេសខ្ពស់មុខខ្ពស់មាត់ ប្តើងកេរ្តិ៍ឈ្មោះកិត្តិយសក្នុងលោកសម័យនោះមិនតិចទេ និងប្រទេសនានាចាប់ផ្តើមស្គាល់ខ្មែរជាហូរហែ ដោយសារសាលារចនានេះឯងដែរ។ ប្រពៃណីរបស់សាលារចនានៅតែបន្តតួនាទីជាប្រក្រតីរៀងរហូតមក បន្ទាប់ពីលោក George Groslier ចាកលោកនេះទៅនៅរវាងឆ្នាំ១៩៤៥។

ចំណេរចេរកាលក្រោយមក ក្នុងបរិយាកាសសង្គមឯករាជ្យ ទឹកចិត្តមនុស្សខ្មែរមានមនសិការខ្ពស់ក្នុងការកសាងជាតិខ្លួន និងស្រឡាញ់សេចក្តីថ្លៃថ្នូរនៅចំពោះមុខអន្តរជាតិនានាក្នុងលោកសម័យថ្មីជំនាន់នោះ គឺសាលារចនាត្រូវរៀបចំពង្រីកឲ្យទៅជាស្ថាប័នអប់រំផ្សព្វផ្សាយផ្នែកសិល្បៈ វប្បធម៌ជាតិកាន់តែទូលំទូលាយ និងខ្ពង់ខ្ពស់ឡើង។ ក្នុងគំនិតដូច្នោះហើយ ទើបព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ ប្រគល់តួនាទីជូនលោកវណ្ណ មូលីវណ្ណ (រូបលេខ៤២) ទទួលបន្ទុកចាត់ចែងរៀបចំសាលារចនាឲ្យក្លាយទៅជា «សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ» (ស.ភ.វ.ស.) តាមព្រះរាជក្រមលេខ២២៦-ប.វ. ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ១៩៦៥។ សាកលវិទ្យាល័យនេះរួមមានមហាវិទ្យាល័យ៥ គឺ៖

១ - មហាវិទ្យាល័យសិល្បៈសូនរូប

២ - មហាវិទ្យាល័យនាដសាស្ត្រ

៣ - មហាវិទ្យាល័យតូរ្យតន្ត្រី

៤ - មហាវិទ្យាល័យបុរាណវិទ្យា

៥ - មហាវិទ្យាល័យស្ថាបត្យកម្មនិងនគរោបនីយវិទ្យា។



៤២. លោក វណ្ណ មូលីវណ្ណ ទទួលបន្ទុករៀបចំសាលារចនាឲ្យទៅជាសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈនៅឆ្នាំ១៩៦៥ និងជាសាកវិទ្យាធិការដំបូង (ប្រភពរូបៈ ?)។

ចាប់ពីពេលក្លាយទៅជាសាកលវិទ្យាល័យមក អ្វីៗកាន់តែធំដុំឡើងៗ និងការកសាងស្រុកទេសក៏កាន់តែត្រូចះត្រូចង់ថែមទៀត ហើយមានលក្ខណៈពិសេសមួយដែលយើងសព្វថ្ងៃហៅថា «អត្តសញ្ញាណ» តាមបែបផែនខ្មែរនាសម័យទំនើប។ សាលារចនានិងសារមន្ទីរក៏នៅតែជាដៃគូជាមួយគ្នាឥតដាច់ ពិសេសផ្នែកសិល្បៈសូនរូប និងបុរាណវិទ្យា ដ្បិតសារមន្ទីរក៏ជាកន្លែងផ្សព្វផ្សាយនិងបណ្តុះបណ្តាល តួយ៉ាងកាលណាសិក្សាពីប្រវត្តិសិល្បៈខ្មែរបុរាណគឺត្រូវចូលទៅសារមន្ទីរជាការចាំបាច់។ បើក្នុងវិស័យថែរក្សា អភិរក្ស ជួសជុលបុរាណវត្ថុផង គឺនិស្សិតបុរាណវិទ្យាត្រូវតែទៅសិក្សានិងអនុវត្តក្នុងរោងជាងសារមន្ទីរជាប្រក្រតី។ រីឯសាស្ត្រាចារ្យនិងអ្នកធ្វើការងារទៀតសោត ក៏ត្រូវការគ្នាទៅវិញទៅមករវាងសារមន្ទីរនិងសាលារចនាដដែល ហើយសូម្បីតែព្រឹទ្ធបុរសមហាវិទ្យាល័យបុរាណវិទ្យាក៏ជួនកាលមាននាទីជាចាងហ្វាងគ្រប់គ្រងសារមន្ទីរថែមទៀតផង ព្រោះវិស័យនេះស្ថិតក្នុងក្របខ័ណ្ឌតែមួយ។ ហើយយ៉ាងហោចណាស់ក៏ចាងហ្វាងសារមន្ទីរ និងមន្ត្រីសំខាន់ៗតែងតែធ្វើសាស្ត្រាចារ្យនៅមហាវិទ្យាល័យបុរាណវិទ្យាដែរ ដ្បិតអ្នកទាំងអស់នោះសុទ្ធតែបានបញ្ចប់ការសិក្សានៅមហាវិទ្យាល័យនេះ ឬក៏ផ្នែកផ្សេងៗក្នុងសាលារចនា។

សាលារចនាបិទទ្វារ អាក់ខានតួនាទីបណ្តុះបណ្តាលធនធានមនុស្ស និងការងារផ្សព្វផ្សាយសិល្បៈ វប្បធម៌របស់ខ្លួនតែក្នុងសម័យខ្មែរក្រហមគ្រប់គ្រងស្រុករវាងឆ្នាំ១៩៧៥-៧៩ប៉ុណ្ណោះ។ បន្ទាប់អំពីនោះមក ដោយមានសេចក្តីសម្រេច លេខ៨៦៨០ក.ម. ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ១៩៨០ ឲ្យចាប់រៀបចំសាលារចនាបន្តិចម្តងៗឡើងវិញ។ ចាប់ពីពេលនោះមក សាលានេះក៏មានដង្ហើមរើបៗឡើងវិញ បន្តជីវិតក្នុងទីតាំងរបស់ខ្លួនដ៏រឹងមាំ និងបន្តកាតព្វកិច្ចដ៏មានខ្លឹមសារជាប្រវត្តិសាស្ត្រចំពោះជាតិខ្លួន។ គ្រានោះស្រុកខ្មែរទាំងមូលនៅមានកម្លាំងកំហែងទន់ខ្សោយនៅឡើយទេ ម៉្លោះហើយសាលារចនាក៏ខិតខំត្រដាបត្រដួសរស់ជាមួយសិល្បករ ស្ថាបត្យករ បុរាណវិទូថ្មីចាស់ កសាងអ្វីៗជាមួយគ្នាដោយមនោសញ្ចេតនាជ្រាលជ្រៅចំពោះសាលានេះ។

លុះមកដល់ថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៨១ ទើបធ្វើពិធីសម្ពោធបើកសាលារចនាជាផ្លូវការឡើងវិញដោយមានឈ្មោះថា «សាលាវិចិត្រសិល្បៈ»។ ពេលនោះការសិក្សាមានតែផ្នែកសិល្បៈសូនរូប និងផ្នែកសិល្បៈសម្តែងផ្សេងៗត្រឹមតែកម្រិតបឋមនិងកម្រិតមធ្យមប៉ុណ្ណោះ។ បន្តិចម្តងៗ សេចក្តីប្រឹងប្រែងរបស់សាស្ត្រាចារ្យចាស់ក្មេងមកពីទីជិតទីឆ្ងាយវិញ ព្រមដោយសិស្សសម័យក្រោយៗនេះ រួមគ្នាជាមួយនឹងថ្នាក់ដឹកនាំក្រសួងឃោសនាការនិងវប្បធម៌ជំនាន់នោះ ក៏ចេះតែធ្វើឲ្យសាលារចនារីកលូតលាស់ថ្កុំថ្កើងជាលំដាប់។

មកដល់ថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៨៨ ទើបមានអនុក្រឹត្យប្រែក្លាយសាលារចនានេះឲ្យទៅជា «សាកលវិទ្យាល័យវិចិត្រសិល្បៈ» ឡើងវិញ។ ចាប់ពីពេលនោះមក ក្រសួងឃោសនាការនិងវប្បធម៌ រួមជាមួយលោកសាកលវិទ្យាធិការ និងសាស្ត្រាចារ្យទាំងឡាយនៃសាលាទាំងមូល ចេះតែពង្រឹងពង្រីកការងារអប់រំបណ្តុះបណ្តាលវិស័យសិល្បៈគ្រប់ជំនាញ, ស្ថាបត្យកម្មនិងនគរោបនីយវិទ្យា, បុរាណវិទ្យា និងការងារស្រាវជ្រាវជាច្រើន។ រហូតមក

ដល់ឆ្នាំ១៩៩៤ ទើបផ្លាស់ឈ្មោះសាកលវិទ្យាល័យនេះឲ្យទៅជា «សាកលវិទ្យាល័យវិចិត្រភូមិន្ទវិចិត្រសិល្បៈ» ដូចដើម។

ដោយសារទីតាំងនិងអគារជាប្រវត្តិសាស្ត្រនេះឆ្លងកាត់រយៈកាលមួយសតវត្សមកហើយ (រូបលេខ៤៣) និងមានការចាស់ទ្រុឌទ្រោមខ្លះ (រូបលេខ៤៤-៤៥) ទើបថ្នាក់ដឹកនាំសាលាតាមជំនាន់នានាខិតខំថែទាំ ជួសជុល និងកែលម្អខ្លះៗជាហូរហែពុំដែលខាន (រូបលេខ៤៦-៤៨)។ រីឯព្រះមហាក្សត្រ ព្រះករុណាព្រះបាទសម្តេចព្រះនោត្តម សីហនុ ព្រះមហាវីរក្សត្រ ទ្រង់ជ្រាបពីការរីកលូតលាស់នេះ ព្រះអង្គក៏សព្វព្រះរាជហឫទ័យប្រោសព្រះរាជទានព្រះរាជទ្រព្យជាមួយនឹងសប្បុរសជនខ្លះ សាងអគារថ្មីមួយថែមទៀតតាមសេចក្តីត្រូវការនៅឆ្នាំ២០០៣ (រូបលេខ៤៩-៥០)។ ការសិក្សានោះក៏ចេះតែចម្រើនលូតលាស់ដល់និស្សិតទាំងឡាយដែលចូលមកសិក្សានៅសាកលវិទ្យាល័យនេះតាមជំនាញផ្សេងៗ សរុបរវាង៤០០-៥០០នាក់ក្នុងមួយឆ្នាំៗ (រូបលេខ៥១)។  នៅរវាងឆ្នាំ២០១២-១៥មកនេះ មានការចាប់



៤៣. អគារខាងមុខរបស់សាលារចនានៅទសវត្ស១៩៩០។



៤៤. អគារសាលារចនានៅទសវត្ស១៩៩០។




៤៥. អគារក្នុងសាលារចនារវាងឆ្នាំ២០០០។



៤៦. អគារសាលារចនាជួសជុលឆ្នាំ២០០៥។



៤៧. អគារខាងមុខរបស់សាលារចនា
កំពុងជួសជុល ឆ្នាំ២០០៦។



៤៨. អគារខាងមុខរបស់សាលារចនា ឆ្នាំ២០១១។



៤៩. អគារថ្មីកំពុងសាងឆ្នាំ២០០៣ ដែលជាព្រះរាជអំណោយរបស់ព្រះករុណាព្រះមហាវីរក្សត្រ។



៥០. អគារថ្មីសាងរួចនៅឆ្នាំ២០០៤ ដែលជាព្រះរាជអំណោយរបស់ព្រះករុណាព្រះមហាវីរក្សត្រ។

ផ្តើមកែលម្អអគារខ្វះ និងពង្រីកបន្ថែមតាមទម្រង់រចនាបថចាស់ជាបណ្តើរៗ ដែលអគារខ្វះកែពង្រីកទៅលើឲ្យមានពីរជាន់ជាហូរហែ (រូបលេខ៥២-៥៤)។ ចំណែកឯអគារដែលជាកន្លែងធ្វើការនិងស្នាក់នៅរបស់លោក George Grolier កាលពីមុននោះ បានកែសម្រួលឲ្យទៅជាការិយាល័យរបស់សាកលវិទ្យាធិការ និងមន្ត្រីផ្នែករដ្ឋបាលគ្រប់គ្រងផ្សេងៗ (រូបលេខ៥៥-៥៦)។



៥១. និស្សិតរៀនគូរគំនូរនៅសាលារចនា ឆ្នាំ២០១៤។



៥២. អគារខាងមុខរបស់សាលារចនា ជួសជុលនិង សាងបន្ថែមឡើងជាពីរជាន់ ឆ្នាំ២០១២-១៥។



៥៣. អគារខាងមុខរបស់ សាលារចនា ឆ្នាំ២០១៥។



៥៤. អគារសាលារចនា សាងបន្ថែមឡើងជាពីរជាន់ ឆ្នាំ២០១២-១៥, ថតពីទិសខាងលិច (ខាងក្នុង)។



៥៥. ផ្ទះលោក George Groslier ស្នាក់នៅធ្វើការក្នុង សាលារចនា បានជួសជុលធ្វើជាការិយាល័យ។



៥៦. ការិយាល័យរបស់សាកលវិទ្យាធិការនៃ សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈបច្ចុប្បន្ន។

«សាលារចនា» ដែលក្លាយទៅជា «សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ» នេះ មានប្រវត្តិវែងឆ្ងាយ១០០ឆ្នាំមកហើយ។ អគារជាច្រើនក្នុងសាលានេះកសាងឡើងតាមលំដាប់លំដោយក្នុងសម័យកាលបន្តបន្ទាប់គ្នា។ អគារចាស់ៗសុទ្ធសឹងតែសាងឡើងតាមរចនាបថខ្មែរ ដំបូលប្រក់ក្បឿងស្រកាលេញ ជញ្ជាំងបូកបាយអលាបពណ៌ក្រហមក្រមៅដូចដីលែង (ពណ៌ដូចគំនូរសម័យបុរេប្រវត្តិរាប់ម៉ឺនឆ្នាំមុន នៅលើផ្ទាំងថ្មតាមភ្នំក្នុងប្រទេសនានា)។ ហោជាងទាំងបីនៅដំបូលមុខខាងកើតនៃអគារសំខាន់នោះ គឺសុទ្ធសឹងតែមានចម្លាក់ក្បូរក្បាច់រចនាយ៉ាងល្អនៅលើឈើ (រូបលេខ៩៨-៩៩)។ នៅពេលជួសជុលកែលម្អអគារនេះរវាងឆ្នាំ



៩៧. ហោជាងកណ្តាល មុខខាងកើតនៃអគារសាលារចនា (រូបព្រះពិស្ណុការ)។



៥៨. ហោជាងខាងត្បូង មុខខាងកើតនៃអគារ សាលារចនា។



៥៩. ហោជាងខាងជើង មុខខាងកើតនៃអគារ សាលារចនា។

២០១២-២០១៥ គឺយើងយកផ្ទាំងហោជាងនិងចម្លាក់ពិចិត្ររចនានោះ ទៅភ្ជាប់តាមកន្ទ្វេង ដើមឡើងវិញ (រូបលេខ៦០-៦២)។ នៅតាមសំយាបដំបូលអគារ សុទ្ធតែមានអែវ៉ាជារូបនាគ មួយគូៗទ្រដំបូលគួរជាទីគាប់ភ្នែក (រូបលេខ៦៣-៦៤)។ នៅតាមកែងសំយាបនានាវិញ មាន អែវ៉ាជារូបកិន្នរ (រូបលេខ៦៥) និងរូបគ្រុឌជ្រែងទ្រដំបូលយ៉ាងប្រណីត ហាក់ដូចជាជួយលើក ស្គួយអគារនេះឲ្យស្រាលអណ្តែតឡើងក្នុងអាកាសដូច្នោះ (រូបលេខ៦៦)។ រីឯរង់ស្បូវនៅតាម អគារនីមួយៗជាបន្ទះក្បាច់ត្របកឈូកមួយជួរវែងក្រោមសំយាបដំបូល (រូបលេខ៦៧)។ សសរទាំងអស់រាងបួនជ្រុង និងមានក្បាលសសរយកគំរូតាមសម័យអង្គរ (រូបលេខ៦៨) ហើយប្រើឈើធ្វើជាគ្រឿងដំបូល ជាធ្នឹម ផ្ទោង ផ្ទាន បង្កង់ ដែរណោង (រូបលេខ៦៩)។



៦០. ហោជាងកណ្ដាល មុខខាងកើតនៃអគារសាលារចនា (រូបព្រះពិស្ណុការ) ដាក់នៅកន្លែងដើមវិញក្រោយពីកែលម្អអគារនេះរួច នៅឆ្នាំ២០១៥។



៦១. ហោជាងខាងត្បូង មុខខាងកើតនៃអគារ សាលារចនា ក្រោយពីកែលម្អអគារនេះរួច។



៦២. ហោជាងខាងជើង មុខខាងកើតនៃអគារ សាលារចនា ក្រោយពីកែលម្អអគារនេះរួច។



៦៣. អែប៉ានិងដៃស្នាទ្រសំយាបដំបូលអគារ សាលារចនា។



៦៤. អែប៉ាជារូបនាគទ្រសំយាបដំបូលអគារ សាលារចនា។



៦៥. អែវ៉ាជារូបកិន្នរទ្រសំយាប
ដំបូលអគារសាលារចនា។



៦៦. អែវ៉ាជារូបគ្រុឌនិងកិន្នរទ្រសំយាបដំបូល
នៅតាមកែងអគារសាលារចនា។



៦៧. ក្បាច់ត្របកឈូកនៅតាមរង់ស្បូវនៃដំបូលអគារសាលារចនា។



៦៨. សសរអគារ
សាលារចនា។



៦៩. ក្បាលសសរនិងគ្រឿងដំបូល
អគារសាលារចនា។

បើមើលពីរបងនិងខ្លោងទ្វារវិញ គឺមានទម្រង់មួយបែប (រូបលេខ៧០-៧២) ក្លាយទៅជាគំរូមួយ ដែលបច្ចុប្បន្នមានគេចូលចិត្តចម្លងយកទៅសាងនៅទីផ្សេងៗដែរ។ នៅលើចម្រឹងដែករបងសាលារចនា មានរូបត្រីសូល៍ (រូបលេខ៧៣) គឺជាត្រាឬសញ្ញារបស់សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈនេះ (រូបលេខ៧៤-៧៥)។ លុះមកដល់ដើមស.វ.ទី២១នេះ សញ្ញាឬត្រារបស់សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈបានដូរមកជារូបព្រះពិស្ណុការ ដែលជាទេពខាងជាងនិងសិល្បៈនានាវិញ (រូបលេខ៧៦)។



៧០. ខ្លោងទ្វារខាងត្បូងរបស់សាលារចនា
មើលពីខាងក្នុង, ឆ្នាំ២០១៥។



៧១. ខ្លោងទ្វារនិងអគារខាងត្បូងរបស់សាលារចនា
មើលពីខាងក្រៅ, ទសវត្ស១៩៩០។




៧២. ខ្លោងទ្វារនិងអគារខាងត្បូងរបស់សាលារចនា
មើលពីខាងក្រៅ, ឆ្នាំ២០១៥។



៧៣. របងសាលារចនាមានសញ្ញារូបត្រីសូល៍នៅខាងចុងចម្រឹងដែក។




៧៤. ត្រាឬសញ្ញារបស់សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ (សាលារចនា) គូរដោយលោកគ្រូ ដេត ចន ឆ្នាំ១៩៦៤។




៧៥. ត្រាឬសញ្ញាលើព្រឹត្តប័ត្ររបស់សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ (សាលារចនា) ទសវត្ស១៩៧០។




៧៦. ត្រាឬសញ្ញារបស់សាលារចនាសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈបច្ចុប្បន្ន។

នៅក្នុងបរិវេណសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈមានរូបព្រះប្រតិមាសំខាន់ៗ មួយចំនួន និងមានរូបចម្លាក់ខ្លះៗទៀតគេដាក់តាំងនៅតាមទីផ្សេងៗ។ ព្រះបរមរូបព្រះបាទជ័យវរ្ម័នទី៧ (រូបលេខ៧៧) ចម្លងតាមរូបបុរាណពិតប្រាកដដែលរក្សាទុកនៅសារមន្ទីរជាតិ

ហើយយករូបចម្លងនោះមកតម្កល់នៅផ្លាសួនចំកណ្តាលដែលមានថៃវព័ទ្ធជុំវិញ។ ព្រះបរមរូបចម្លងដែលដាក់តម្កល់នៅទីនេះក្លាយទៅជាទីសក្ការៈបូជារបស់សាស្ត្រាចារ្យ មន្ត្រីរាជការ និស្សិត និងមនុស្សម្នាទាំងពួង (រូបលេខ៧៨)។ រូបនេះសាងឡើងនៅទសវត្ស១៩៨០ គឺជាលើកដំបូងហើយ ដែលគេចាប់ផ្តើមចម្លងព្រះបរមរូបព្រះបាទជ័យវរ្ម័នទី៧ យកមកដាក់តម្កល់ក្នុងសាលារចនា។ គំនិតដូច្នេះក៏ចាប់ផ្តើមមានជាបន្តបន្ទាប់ទៅទីផ្សេងៗតាមគំរូ



៧៧. ព្រះបរមរូបព្រះបាទជ័យវរ្ម័នទី៧ ចម្លងដំបូងគេតម្កល់នៅសាលារចនា ទសវត្ស១៩៨០។



៧៨. ព្រះបរមរូបព្រះបាទជ័យវរ្ម័នទី៧ (រូបចម្លង) តម្កល់នៅក្នុងសាលារចនា ដែលគេគោរពបូជាមកដល់សព្វថ្ងៃ។

សាលារចនានេះ ហើយរហូតមកដល់សព្វថ្ងៃរឹតតែមាននៅស្ទើរពាសពេញស្រុកខ្មែរ។ នៅទិសខាងកើតពីមុខអាគារសាលារចនា មានតម្កល់រូបព្រះគណេសតាំងពីមុនសម័យខ្មែរក្រហមមកម្ល៉េះ (រូបលេខ៧៩)។ រីឯនៅទីផ្លាសួនខាងលិចឯនោះវិញ មានរូបព្រះពិស្ណុការ (ទើបសាងរវាង៧-៨ឆ្នាំមុននេះ) តម្កល់ក្នុងមណ្ឌបមានកំពូលស្រួចទៅលើ (រូបលេខ៨០)។



៧៩. រូបព្រះគណេស (រូបចម្លង) តម្កល់នៅមុខអគារសាលារចនា ដែលគេគោរពបូជាមកដល់សព្វថ្ងៃ។



៨០. រូបព្រះពិស្ណុការ (សាងថ្មី) តម្កល់ក្នុងមណ្ឌបនៅសាលារចនា។

នៅរវាងឆ្នាំ១៩៦៨-៦៩ គេបានបង្កើតព្រឹត្តប័ត្រនិស្សិតមហាវិទ្យាល័យបុរាណវិទ្យាសម្រាប់ចុះផ្សាយអត្ថបទស្រាវជ្រាវផ្សេងៗរបស់មហាវិទ្យាល័យនេះ ហើយបោះពុម្ពផ្សាយមួយលេខក្នុងមួយឆ្នាំ។ នៅលើក្របមុខនៃព្រឹត្តប័ត្រនេះគេដាក់រូបគំនូរព្រះសិរព្រះបាទជ័យវរ្ម័នទី៧ ដើម្បីធ្វើជាសញ្ញាសម្គាល់ (រូបលេខ៨១)។ ការយករូបព្រះសិរព្រះបាទជ័យវរ្ម័នទី៧ទៅធ្វើជានិមិត្តសញ្ញា ឬធ្វើជាត្រាផ្សេងៗដែលទាក់ទងនឹងប្រវត្តិសាស្ត្រនិងវប្បធម៌ជាដើម ក៏ចាប់សាយភាយចេញពីសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈនេះមុនគេ (ពិសេសពីមហាវិទ្យាល័យបុរាណវិទ្យាដែលសិក្សាពីប្រវត្តិសាស្ត្រ និងប្រវត្តិសិល្បៈខ្មែរបុរាណ) គឺតាំងពីរវាងទសវត្ស១៩៦០នោះរហូតមក។ បច្ចុប្បន្នក្រសួងវប្បធម៌និងវិចិត្រសិល្បៈក៏មាននិមិត្តសញ្ញាជារូបព្រះសិរព្រះបាទជ័យវរ្ម័នទី៧ដូច្នោះដែរ (រូបលេខ៨២) ហើយស្ថាប័នតូចធំឬកម្មវិធីខ្លះមានដាក់រូបរបៀបនេះជាច្រើន។










៨១. សញ្ញាឬត្រារបស់ព្រឹត្តបត្រនិស្សិតមហាវិទ្យាល័យបុរាណវិទ្យា រូបព្រះសិរព្រះបាទជ័យវរ្ម័នទី៧ តាំងពីទស្សវត្សរ៍១៩៦០-៧០ (រូបខាងឆ្វេង) និងទសវត្សរ៍១៩៩០-២០០០ (រូបខាងស្តាំ)។

៨២. សញ្ញារបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ (បច្ចុប្បន្ន) រូបព្រះសិរព្រះបាទជ័យវរ្ម័នទី៧។

ចាប់ពីកកើតដំបូងរហូតមក សាលារចនានិងសារមន្ទីរនៅតែស្ថិតក្នុងមណ្ឌលមួយជាប់គ្នា គឺពុំមានខ័ណ្ឌជារបងដាច់ស្រឡះពីគ្នាទេ នៅពេលដែលសាលានេះក្លាយទៅជាសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈក៏ដោយ (គ្រាន់តែមានអគារដាច់ចេញពីគ្នា)។ នៅទសវត្សរ៍១៩៨០-១៩៩០ទីធ្លាស្ថាប័នទាំងពីរ គ្រាន់តែមានព្រំជារុក្ខជាតិលម្អខ្វះចែកទីតាំងគ្រប់គ្រងផ្សេងពីគ្នាប៉ុណ្ណោះ។ ចាប់តាំងពីដើមមក នៅត្រង់ទីធ្លាដីផ្នែកខាងត្បូងនៃអគារសារមន្ទីរជាតិមួយភាគ គឺជាវាលសម្រាប់និស្សិតសាលារចនាគោរពទង់ជាតិ និងលេងកីឡា ឬធ្វើកិច្ចការផ្សេងៗ (រូបលេខ៨៣)។ លុះមកដល់រវាងឆ្នាំ២០០៣ ទើបចាប់មានខ័ណ្ឌជារបងពុះចែកបរិវេណដីដាច់ស្រឡះពីគ្នាចាប់ពីទិសខាងត្បូងរត់ត្រង់ទៅទិសខាងជើង ដូចឃើញ

មានមកដល់បច្ចុប្បន្ននេះស្រាប់ (រូបលេខ៨៤)។ ប៉ុន្តែមិនយូរប៉ុន្មាន លោកសាស្ត្រាចារ្យ ឃុន សាម៉េន ដែលជាចាងហ្វាងសារមន្ទីរជាតិជំនាន់នោះ និងជាសាស្ត្រាចារ្យបង្រៀននៅមហាវិទ្យាល័យបុរាណវិទ្យាផង ក៏បើករបងធ្វើជាខ្លោងទ្វារមួយ ដែលអាចចេញចូលទៅមករវាងសាលារចនានិងសារមន្ទីរនេះឡើងវិញ (រូបលេខ៨៥)។ នេះមកពីលោកសាស្ត្រាចារ្យយល់ឃើញជាក់ស្ដែងថា ស្ថាប័នទាំងពីរមានទំនាក់ទំនងគ្នាជិតស្និតទាំងខាងការសិក្សា ទាំងខាងការងារបច្ចេកទេស និងកិច្ចការផ្សេងៗជាច្រើន ដែលស្ថិតក្នុងបរិបទតែមួយដូចកាលគ្រាដើមតរហូតមកដល់សព្វថ្ងៃនេះដដែល។



៨៣. ទីធ្លាមុខខាងកើតសាលារចនាពុំទាន់ខ័ណ្ឌជារបងដាច់ពីសារមន្ទីរ នៅមុនឆ្នាំ២០០៣។



៨៤. របងខ័ណ្ឌបរិវេណដាច់ចេញពីគ្នារវាងសាលារចនានិងសារមន្ទីរ នៅឆ្នាំ២០០៣។




៨៥. ច្រកសម្រាប់ចេញចូលទៅមករវាងសាលារចនានិងសារមន្ទីរ។

ចំពោះការសិក្សារៀនសូត្រនៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈបច្ចុប្បន្ននេះវិញ និស្សិតមានឱកាសសិក្សាបានច្រើន គឺមានរៀនតាមថ្នាក់រៀងៗខ្លួនហើយ តែងមានម៉ោងចូលរួមស្តាប់បាឋកថាទៅតាមកម្រិតថ្នាក់និងជំនាញផ្សេងៗទៀត។ ក្រៅពីនោះមានបាឋកថាសាធារណៈនៅក្នុងសាកលវិទ្យាល័យនេះផង ពោលគឺរវាង១០ទៅ១៥ដងថែមទៀតក្នុងមួយឆ្នាំៗ។ បន្ទាប់ពីសិក្សានៅក្នុងសាលាហើយ តែងមានដំណើរកម្មសិក្សាទៅតាមតំបន់នានាតាមជំនាញរបស់ខ្លួន និងទៅតាមកម្រិតថ្នាក់របស់និស្សិតក្នុងមហាវិទ្យាល័យនីមួយៗ។ នៅរៀងរាល់ឆ្នាំនិស្សិតមានឱកាសប្រឡងទៅចូលរួមហ្វឹកហ្វឺនការងារជំនាញផ្សេងៗជាមួយនឹងស្ថាប័ននានាជាច្រើន ឯអ្នកខ្លះទៅធ្វើកម្មសិក្សានៅក្រៅប្រទេសទៀតផងក៏មានរៀងរាល់ឆ្នាំដែរ។ នៅពេលបញ្ចប់ការសិក្សាគ្រប់មហាវិទ្យាល័យទាំង៥ក្នុងសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ គឺនិស្សិតត្រូវតែធ្វើសារណាមួយច្បាប់ និងបង្ហាញស្នាដៃរបស់ខ្លួនក្នុងកម្មវិធីទ្រទ្រង់សារណាជាឱឡារិក ដែលចូលរួមពីគណកម្មការកំណែគ្រប់ជាន់ថ្នាក់ (រូបលេខ៨៦)។

មកដល់ពេលនេះសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈបានបណ្តុះធនធានមនុស្សក្នុងវិស័យ សិល្បៈគ្រប់ផ្នែក, ស្ថាបត្យកម្មនិងនគរោបនីយវិទ្យា, វប្បធម៌ និងបុរាណវិទ្យាជាដើម រាប់ពាន់នាក់ ហើយបានចូលទៅក្របកការងារផ្សេងៗក្នុងសង្គម និងបម្រើការងារជាមន្ត្រីរាជការ តាមលំដាប់ថ្នាក់ផ្សេងៗជាច្រើននៅស្ថាប័ននានាទូទាំងប្រទេស។




៨៦. សម្តេចព្រះរាជបុត្រីព្រះរៀម នរោត្តម បុប្ផាទេវី រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ យាងជាព្រះអធិបតីក្នុងពិធីទ្រទ្រង់សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រនិស្សិតមហាវិទ្យាល័យបុរាណវិទ្យា ឆ្នាំ២០០០ (រូបខាងឆ្វេង) និងពិធីទ្រទ្រង់សារណារបស់និស្សិតឆ្នាំ២០១៤ (រូបខាងស្តាំ)។

សាស្ត្រាចារ្យចាស់ក្មេង និងនិស្សិតចាស់ថ្មីនៅសាលានេះតែងតែមានមនោសញ្ចេតនាស្រឡាញ់សាលារបស់ខ្លួនយ៉ាងជ្រាលជ្រៅស្មើរគ្រប់គ្នា។ ជារៀងរាល់ឆ្នាំ គឺនៅចំថ្ងៃព្រហស្បតិ៍ មុនថ្ងៃបុណ្យចូលឆ្នាំថ្មី តែងធ្វើពិធីសំពះគ្រូ ធ្វើបុណ្យធ្វើទានរួមគ្នា (រូបលេខ៨៧-៨៩) តាំងពិព័រណ៍បង្ហាញស្នាដៃ (រូបលេខ៩០-៩២) និងសម្តែងសិល្បៈផ្សេងៗតាមជំនាញរៀងៗខ្លួនរយៈពេល៣ថ្ងៃពុំដែលខាន (រូបលេខ៩៥-៩៦)។ ក្នុងឱកាសដែលមានព្រឹត្តិការណ៍



៨៧. ពិធីបុណ្យសំពះព្រះខែនិងអកអំបុក (ពេលយប់) នៅសាកលវិទ្យាល័យភូមិន្ទ វិចិត្រសិល្បៈ ទសវត្ស១៩៩០។



៨៨. ពិធីសូត្រមន្តបុណ្យចូលឆ្នាំថ្មីនៅសាកលវិទ្យាល័យ ភូមិន្ទវិចិត្រសិល្បៈ ឆ្នាំ២០១៥។




៨៩. ពិធីសូត្រមន្ត រាប់បាត្របុណ្យចូលឆ្នាំថ្មី និងស្រង់ទឹកថ្វាយព្រះបរមរូបព្រះបាទជ័យវរ្ម័នទី៧ នៅក្នុងសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ឆ្នាំ២០១៥។



៩០. តាំងពិព័រណ៍របស់និស្សិតមហាវិទ្យាល័យ
បុរាណវិទ្យា ឆ្នាំ២០១៤។




៩១. តាំងពិព័រណ៍របស់និស្សិតមហាវិទ្យាល័យ
ស្ថាបត្យកម្មនិងនគរោបនីយវិទ្យា ឆ្នាំ២០១៤។



៩២. តាំងពិព័រណ៍របស់និស្សិតមហាវិទ្យាល័យ
ស្ថាបត្យកម្មនិងនគរោបនីយវិទ្យា ឆ្នាំ២០១៥។



៩៣. តាំងពិព័រណ៍របស់និស្សិតមហាវិទ្យាល័យ
សិល្បៈសូនរូប ឆ្នាំ២០១៤។



៩៤. តាំងពិព័រណ៍របស់និស្សិត ឆ្នាំ២០១៤។



៩៥. សម្តែងសិល្បៈរបស់និស្សិតមហាវិទ្យាល័យ
តូរ្យតន្ត្រី នាដសាស្ត្រ និងចម្រុះគ្នា ឆ្នាំ២០១៤។



៩៦. សម្តែងសិល្បៈរបស់និស្សិតមហាវិទ្យាល័យតូរ្យតន្ត្រី និងនាដសាស្ត្រ ឆ្នាំ២០១៤។



៩៧. និស្សិតនិងភ្ញៀវចូលមកធ្វើបុណ្យ និងមើលការសម្តែងសិល្បៈក្នុងសាលារចនា ឆ្នាំ២០១៤។

ផ្សព្វផ្សាយសិល្បៈ វប្បធម៌ និងការស្រាវជ្រាវទាំងឡាយនេះ តែងតែមានមនុស្សម្នាដែលជាមិត្តភក្តិនិងភ្ញៀវរបស់និស្សិត ឬរបស់សាស្ត្រាចារ្យមកពីទីជិតទីឆ្ងាយ ព្រមទាំងសិស្ស និស្សិតមកពីសាលានានា រួមទាំងភ្ញៀវទេសចរជាតិសាសន៍ផ្សេងៗមកចូលទស្សនារាប់ពាន់នាក់ជានិច្ច (រូបលេខ៩៧-៩៨)។ តាមពិតទៅ សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈឬហៅថាសាលារចនា ដែលស្ថិតនៅទីនេះក្លាយទៅជា «អត្តសញ្ញាណជាតិខ្មែរ» មួយស្រេចទៅហើយ។ សូម្បីតែនៅពេលមានភ្ញៀវបរទេសដែលជាថ្នាក់ដឹកនាំធំៗអញ្ជើញមកស្រុកខ្មែរ ក៏ជួនកាលយើងរៀបចំដំណើរទស្សនកិច្ចរបស់គេឲ្យបានចូលមកទស្សនាសាលារចនាដែរ ពោលគឺក្នុងន័យថាដើម្បីលើកមុខលើកមាត់ជាតិតាមរយៈសាលាសិល្បៈដ៏ល្បីល្បាញនេះ (រូបលេខ៩៩)។

និស្សិតសាកលវិទ្យាល័យផ្សេងៗ និងអ្នកភូមិផងរបងជិតខាងនឹងសាលានេះតែងតែមានចិត្តមានថ្លើមស្រឡាញ់រាប់រកគ្នា ធ្វើសេចក្តីល្អជាមួយគ្នាជុំវិញទីតាំងនិងក្រោមកេរ្តិ៍ឈ្មោះថា «សាលារចនា» នេះឯង (រូបលេខ១០០)។




៩៨. និស្សិតចាំទទួលភ្ញៀវចូលមកទស្សនាពិព័រណ៍
នៅសាលារចនា ឆ្នាំ២០១៥។



៩៩. ជំទាវភរិយាប្រធានាធិបតីនិងនាយករដ្ឋមន្ត្រីប្រទេសក្នុងតំបន់អាស៊ាន និងប្រទេសខ្លះក្នុងទ្វីបអាស៊ី
អញ្ជើញមកទស្សនាសាលារចនា ដែលយើងចាត់ទុកថាជាអត្តសញ្ញាណមួយរបស់ជាតិខ្មែរ, ឆ្នាំ២០១២។



១០០. សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ (សាលារចនា) មើលពីទិសខាងជើងទៅ ឃើញកំពូលព្រះទីនាំងទេវាវិនិច្ឆ័យនៃព្រះបរមរាជវាំង (ប្រភពរូបៈ ស្រង់ពី Marie-francoise Le Guen-Chatel)។

ខ្ញុំសូមបញ្ចប់សេចក្តីសង្ខេបយ៉ាងអំពីសាលារចនាតែត្រឹមនេះចុះ។ បើលោកអ្នកអានចង់យល់ដឹងបន្ថែមអំពីដំណើរវិវឌ្ឍ, កេរ្តិ៍ឈ្មោះ, តម្លៃខាងប្រវត្តិសាស្ត្រ, សិល្បៈ និងវប្បធម៌របស់សាលារចនា ដែលល្បីល្បាញរហូតដល់មានការសិក្សាស្រាវជ្រាវវែងឆ្ងាយល្អិតល្អន់តាំងពីរវាង១០០ឆ្នាំមុនរហូតមកដល់សព្វថ្ងៃនេះ សូមអញ្ជើញរកអានឯកសារផ្សេងៗជាច្រើន ដូចមានបញ្ជីឯកសារពិគ្រោះជូនភ្ជាប់ខ្លះៗមកជាមួយនេះ។

# ឯកសារពិគ្រោះ

- ព្រឹត្តិបត្រពត៌មានពីសកម្មភាពឃោសនាការនិងវប្បធម៌, លេខ៥, ឆ្នាំ១៩៨៣។

- គម្រោងផែនការ ក្រសួងឃោសនាការនិងវប្បធម៌ ឆ្នាំ១៩៨៦។

- ព្រឹត្តិបត្រនិស្សិតមហាវិទ្យាល័យបុរាណវិទ្យា, លេខ១, ខែវិច្ឆិកា ឆ្នាំ២០០០។

- សៀវភៅ «ខ្មែរប្រឈមមុខនឹងវប្បធម៌» បោះពុម្ពផ្សព្វផ្សាយដោយ វៃឃំ, ២០០១។

- អ៊ុំ ច័ន្ទណារ៉ាត, ចំលាក់ទំនើប, និក្ខេបបទបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រមហាវិទ្យាល័យសូនរូប, ១៩៩៤-៩៤។

Cérémonie D'inauguration du Musée Albert Sarraut et de L'école des Arts Cambobgiens, Imprimerie du Protectorat, Phnom Penh, 1920.

Anonyme. « École des arts cambodgiens », rubrique « Chronique », *Arts et Archéologie khmers* 1 (1921-23).

Anonyme. *Inauguration du Musée Albert Sarraut et de l'École des arts cambodgiens*. Phnom Penh : Imprimerie du Protectorat, 1920.

Anonyme. « Le Service des Arts cambodgiens », *Arts et Archéologie khmers* 1 (1921-23).

Abbe, Gabrielle. « La 'rénovation des arts cambodgiens' ». *Bulletin de l'Institut Pierre Renouvin* 1 (2008) (27) : 61-76.

Abbe, Gabrielle. « Eléments pour l'histoire du musée Albert Sarraut de Phnom Penh ». *Siksacakr, Journal of Cambodia Research* 12-13 (2010-11) : 219-234.

Cooper, Nicola. *France in Indochina : Colonial Encounters*. Oxford, New York : Berg, 2001.

Demay, Aline. « De la sala des voyageurs au palace : L'industrie hôtelière dans le Angkor colonial ». *Siksacakr, Journal of Cambodia Research* 12-13 (2010-2011) : 179-192.

Dulucq, Sophie, Klein, Jean-François et Stora, Benjamin, dir. *Les mots de la colonisation*. Toulouse : Presses Universitaires du Mirail, 2007.

Edwards, Penny. *Cambodge : The Cultivation of a Nation, 1860-1945*. Honolulu : University of Hawai'i Press, 2006.

Forest, Alain. *Le Cambodge et la colonisation française (1897-1920)*. Paris : L'Harmattan, 1980.

Gabrielle Abbe, LE DÉVELOPPEMENT DES ARTS AU CAMBODGE À L'ÉPOQUE COLONIALE : GEORGE GROSLIER ET L'ÉCOLE DES ARTS CAMBODGIENS (1917-1945), *UDAYA, Journal of Khmer Studies, 12, 2014.*

Groslier, George. *Danseuses cambodgiennes, anciennes et modernes*. Paris : Challamel, 1913.

Groslier, George. *À l'ombre d'Angkor : notes et impressions sur les temples inconnus de l'ancien Cambodge*. Paris : Challamel, 1916.

Groslier, George. « La tradition cambodgienne ». *Revue indochinoise* XXIX, (5) (mai 1918).

Groslier, George. « L'agonie de l'art cambodgien ». *Revue indochinoise* XXIX, (6) (juin 1918).

Groslier, George. « La prise en charge des arts cambodgiens ». *Revue indochinoise* XXX, (septembre 1918).

Groslier, George. *La convalescence des arts cambodgiens*. Hanoi, Imprimerie d'Extrême-Orient, 1919.

Groslier, George. « Etude sur la psychologie de l'artisan cambodgien ». *Arts et Archéologie khmers* 1 (2), (1921) : 125-137.

Groslier, George. « Seconde étude sur la psychologie de l'artisan cambodgien ». *Arts et Archéologie khmers* 1 (2), (1921) : 205-220.

Groslier, George. « Ce qui a été fait au Cambodge pour la pratique et la protection des arts indigènes. I. Historique du Service des Arts ». *Arts et Archéologie khmers* 1 (1921-1923).

Groslier, George. « La reprise des arts khmers ». *La Revue de Paris* (1925).

Groslier, George. *Le retour à l'argile*. Paris : Emile Paul Frères, 1928.

Groslier, George. « L'Enseignement et la mise en pratique des Arts indigènes au Cambodge (1918-1930) ». *Bulletin de l'Académie des Sciences Coloniales* XVI. Paris : Société d'éditions Géographiques, Maritimes et Coloniales, 1931.

Groslier, George. *Eaux et lumières : journal de route sur le Mékong cambodgien*. Paris : Société d'Éditions Géographiques, Maritimes et Coloniales, 1931.

Herbelin, Caroline. « Deux conceptions de l'histoire de l'art en situation coloniale : George Groslier (1887-1945) et Victor Tardieu (1870-1937) ». *Siksacakr, Journal of Cambodia Research* 12-13 (2010-2011) : 206-218.

Klein, Jean-François. « Le général de Beylié : un acteur singulier de la patrimonialisation indochinoise ? ». *Siksacakr, Journal of Cambodia Research* 12-13 (2010-2011) : 167-178.

Marchal, Henri. « L'art cambodgien moderne ». *Bulletin de la Société des Etudes indochinoise* 65 (2è semestre 1913) : 69-75.

Mikaelian, Grégory. « Compte-rendu de Thiounn, Voyage du roi Sisowath en France en l'année du cheval, huitième de la décade, correspondant à l'année occidentale 1906 ». *Péninsule* 56 (1) (2008) : 209-217.

Morlat, Patrice. « Projets coloniaux et mise en pratique : la politique des « fils » de Sarraut en Indochine dans les années vingt ». *Cahiers d'histoire. Revue d'histoire critique* 85 (2001) : 13-28.

Moura, Jean. « Etat actuel des arts au Cambodge ». *Le royaume du Cambodge* II (1883) : 401.

Muan, Ingrid. *Citing Angkor : the "Cambodian Arts" in the Age of Restoration 1918-2000*. Ph.D. dissertation, Columbia University, 2001.

Polkinghorne, Martin ; Vincent, Brice ; Thomas, Nicolas ; et Bourgarit, David. « Casting for the king : the Royal Palace bronze workshop of Angkor ». *Bulletin de l'École française d'Extrême- Orient* 100 (à paraître).

Thiounn, Oknha Veang. *Voyage du roi Sisowath en France en l'année du cheval, huitième de la décade, correspondant à l'année occidentale 1906, traduit du khmer, présenté et annoté par Olivier de Bernon*. Paris : Mercure de France, 2006.

Vincent, Brice. « Le mobilier en bronze du palais royal d'Angkor Thom ». *Aséanie* 33 (2014) (à paraître).